ញ៉ុក . ថែម

# មហាវេស្សន្តរជាតក



## ភាគទី ៥

ផ្សាយចេញពី "បណ្ណាគារ[illegible]"
រក្សាសិទ្ធិគ្រប់យ៉ាង
ព.ស ២៥៤៦ គ.ស ២០០២

# មហាវេស្សន្តរជាតក

## សម្រាប់ទេសន៍

## ទី ៥

# កណ្ឌជូជក

ប្រដាប់ដោយគាថា ៥៩
បោះពុម្ពលើកទី ១
ចំនួន ១.០០០ ច្បាប់


## ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស ២៥០៩



Websites: WatKhemaraRatanaram.org or WatKhmers.org

# មហាវេស្សន្តរជាតក

## ទី ៥

## **កណ្ឌជូជក**

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

តទា កាលិង្គរដ្ឋេ ទុន្នវិដ្ឋព្រាហ្មណគាមវាសី ជូជកោ នាម ព្រាហ្មណោ ភិក្ខាចរិយាយ កហាបណសតំ លភិត្វា ឯកស្មឹ ព្រាហ្មណកុលេ ឋបេត្វា បុន ធនំ បរិយេសនត្ថាយ គតោ ។ តស្មឹ ចិរាយន្តេ ព្រាហ្មណកុលំ កហាបណេ វលញ្ជេត្វា បច្ឆា ឥតរេន អាគន្ត្វា ចោទិយមានំ កហាបណេ ទាតុំ អសក្កោន្តំ អមិត្តតាបនំ នាម ធីតរំ តស្ស អទាសិ ។

តទា កាលេ ។ នាកាលព្រះបរមពុទ្ធង្កុរបណ្ដូលជិនវង្ស ដ៏ជាអង្គព្រះជិនស្រី ក្សត្រាក្សត្រីទាំង ៤ ព្រះអង្គ ស្ដេចចេញចោល ព្រះញាតិវង្ស ទៅទ្រង់ព្រឹទ្ធនៅភ្នំគិរីវង្កត ដ៏ជាទីរហោឋានពុំមានម្រឹគ ពាឡយង់ឃ្នងមកប៉ងបៀតបៀនពាធា ។ ឯកោ ព្រាហ្មណោ មាន

ព្រាហ្មណ៍ម្នាក់ឈ្មោះជូជកព្រឹទ្ធាចារ្យ រូបអន្ធការ ស្គមច្រដោង ច្រមុះកោង ទ្រូងសឹងតែផ្អឹង សក់រឹងក្រញាង ពោះធំកំប៉ោង លោងសំពៀត ជំបារត្រចៀកយុរយារក្រាស់ដូចឃ្លង់ភ្លើង ជើងកោងដូចជើងសេក ភ្នែកស្រលៀងស្រឡើ សាច់ពកដូចគេផ្ទើរដិបរដុបយុរយារប៉ុន ៗ ផ្លែក្រសាំង ផ្លែសម៉ ធ្មេញស ក្បាលវែងតូចម្ខាងដូចផ្លែញ្ញៅ ។ គាត់នៅស្រុកទុន្នវិដ្ឋព្រាហ្មណ៍គ្រាម ជិតនឹងស្រុកកាលិង្គរាស្ត្រ គាត់តែងនឹងដើរសូមទានគេ ថាបើពុំបានឯស្រុក គាត់ទៅឯវត្តអ្នកយើង ពុំបានឯជើង គាត់ទៅឯត្បូង ពុំបានឯទ្រទូង គាត់ទៅឯសាមណេរ ពុំបានឯថេរ គាត់ទៅឯដូនជី ។ គាត់ដើរសូមតែគេឆីដោយសព្វជើងជណ្ដើរ គាត់សូមទាំងត្រីឆ្អើរ ត្រីងៀត ត្រីប្រៃ ស្លឹកគ្រៃ ខ្ញី ម្រេច ម្ទេស អំពិល ក្រសាំង អំបិល ពុំឲ្យសល់ដល់មួយមុខឡើយ ។ គាត់សូមបានមកស្រេចហើយ គាត់សន្សំប្រកទុកក្នុងថង់យាមធំ គាត់ដើររកសូមគ្រប់ផ្សារផ្សេ្រ គ្រប់ស្រុក សូមទាំងប្រហុកផ្អកមុាំ សន្សំប្រកទុកក្នុងឆ្នាំង សូមទាំងស្លាម្លូ ស្លាជ្វា កំបោរ ថ្នាំ តាមតែចិត្តនឹក សូមទាំងផ្លូវទឹក ផ្លូវគោក ហើយគាត់ដឹងទាំងយាមយោគយាត្រា ចេះគន់គូរជតារាសី

Websites: WatKhemaraRatanaram.org or WatKhmers.org

ចេះស្រដីផ្សេងៗរំញាលចិត្ត ។ គាត់ដើរសូមមួយថ្ងៃ ១០ ត្រឡប់, លុះតែបានគ្រប់ហ្វូងស្លឹង គិតជាមាសបាន ១០០ តម្លឹង ជាលាភតាព្រឹទ្ធាចារ្យ គាត់នឹងរាប់ទុកក្រែងវាខូចអសារឥតការ នឹងផ្ញើទុកនៅអ្នកឯណាពុំបាន នឹងយកជាប់ទៅដោយខ្លួនប្រាណក៏តែម្នាក់ឯង ក្រែងជួនប្រទះនឹងសត្រូវវាប្លន់យក ។

សហាយកោ អើសម្លាញ់យើងក៏មាននៅនាឋាននេះ ល្មមទុកចិត្តផ្ញើទ្រព្យក៏បានអេះ ។ គាត់គិតស្រេចដូច្នោះហើយ ទើបគាត់យកមាសមកច្រកថង់ចងខ្ជាប់ស្រេច ហើយពុំលង់ឡើយ តាព្រឹទ្ធាចារ្យយកទៅផ្ញើនឹងត្រកូលព្រាហ្មណ៍ប្ដីប្រពន្ធទាំងពីរនាក់ ។ ទើបជូជកគាត់និយាយផ្ដាំថា «នែសម្លាញ់អើយ មាសអញ ១០០ តម្លឹងនេះ អញសុំផ្ញើនឹងអ្នក បើអញសុខសប្បាយពុំគ្រុនរងាទេ អញវិលមកដល់កាលណា អញនឹងសុំយកអំពីអ្នកក្នុងកាលនោះ» ។ ឯត្រកូលព្រាហ្មណ៍ទាំងពីរ រាប់មើលឃើញជាក់ហើយ ក៏ទទួលយកមាសតាព្រឹទ្ធាចារ្យទៅរក្សាទុក ។ ឯតាជូជក គាត់ទៅស្វែងរកលាភសព្វឋានឲ្យបានវិញទៀតហោង ។ បពិត្រអើយ រីឯមាសតាជូជកដែលគាត់ផ្ញើឲ្យត្រកូល

ព្រាហ្មណ៍ទាំងពីររក្សាទុកនោះ ឧបមាបីដូចអ្នកយកភ្លើងមកដាក់ក្នុងផ្ទះ ឲ្យកើតក្ដៅក្រហាយពុំក្សេមក្សាន្ត ទោះទ្រព្យអំពីដើមប៉ុន្មានៗ ក្ដីក៏យកចេញចាយពុំមានសេសសល់សំណាស់ដល់តិចឡើយ ហើយវាកើតជាទុពិលពន់ប្រមាណ មានតែខ្លួនប្រាណប្ដីប្រពន្ធនិងកូនក្រមុំមួយជាបីនាក់ ទើបគិតថា មាសតាព្រឹទ្ធាចារ្យដែលគាត់ផ្ញើនឹងយើងនោះឥឡូវគាត់បាត់យូរឆ្នាំណាស់ហើយ ពុំនោះឡើយក្រែងគាត់ស្លាប់បាត់ខ្ចាត់ខ្ចាយ ទើបពុំឃើញវិលមកទារមាសវិញឡើយ ។ បើដូច្នោះហើយមានតែយើងនឹងយកមាសដែលគាត់ផ្ញើទុក ទៅទិញឆីចុកលលក់ទន្ទិញ បើគាត់វិលមកកាលណាមិញ សន្សំមយើងរកសងឲ្យគាត់ ។ គិតស្រេចដូច្នោះហើយ ពុំលង់ឡើយក៏យកមាសទៅចាយវាយ ឆីចុកអស់ទៅ ឥតសេសសល់សំណល់ដល់តិចឡើយ ។

បច្ឆា ឥតវេដ អាគន្ត្វា ។ បពិត្រអើយ រីឯតាជូជកចាស់ជរា ស្វែករកទ្រព្យរៀងៗ មក បានគ្រប់ហើយ គាត់ត្រឡប់វិលមករកត្រកូលព្រាហ្មណ៍ទាំងពីរវិញ ហើយទើបដណ្ដឹងថា «អើសម្លាញ់ មាសអញដែលផ្ញើទុកនឹងអ្នក អញសុំយកអំពីអ្នកឥឡូវនេះហោង» ។ ឯ

Websites: WatKhemaraRatanaram.org or WatKhmers.org

ត្រកូលព្រាហ្មណ៍ប្ដីប្រពន្ធធ្វើជាស្រដីថា អើអ្នកតា មកដល់ហើយហ: ឱតាអើយ ពីក្រោយអ្នកតាទៅនោះ ខ្ញុំមានសេចក្ដីក្រលំបាកតោកយ៉ាកពេកពន់ប្រមាណ ។ អម្ចាស់ខ្ញុំអើយ នឹងរកអ្វីធីបន្ដិចបន្ដួចក៏ពុំបាន ពីតូចខ្ញុំកើតមកពុំដែលខ្សត់ដល់ម្ល៉េះឡើយ ។ អម្ចាស់ខ្ញុំអើយ មាសដែលអម្ចាស់ផ្ញើទុកនឹងខ្ញុំនោះ ខ្ញុំយកទៅលក់ដូរឆីចុកអស់ហើយអម្ចាស់, ហើយអម្ចាស់ខ្ញុំអើយ ថាបើដល់ឆ្នាំត្រជាក់ជើងដៃ ខ្ញុំបានស្រូវស្រែស្រូវចំការ ជួញប្រែលលក់ទន្និញបានកាលណាមិញ សន្សំខ្ញុំសងអ្នកតាកាលនោះ ។

ឯជូជកព្រាហ្មណ៍ ពោលឡើងថា ស្រដីដូច្នោះរួចហ្ន:! ព្រាហ្មណ៍ក្រេវក្រោធចងចញ្ចើមជិត ដៃចាប់ឈើច្រត់និងយាមស្រដីគម្រាមគង្គួន គាត់ធ្វើជាមួនទួនមាំទាំ ខាំមាត់ក្រអឺត ស្លើតទាំងត្របកភ្នែក ដូចគេហែកឡើងទៅលើ ។ គាត់ធ្វើមែនទែនមាំទាំទៀងទាត់ គាត់លាត់ទាំងសំពត់បង្ហាញទាំងដុំដៃទៅព្រាហ្មណ៍ ស្រដីគម្រាមថា នែបើពុំបានឲ្យអញ ៗ ពុំលែងឡើយ បើអញចូលទៅហើយ អញនឹងប្ដឹងចៅក្រម ឲ្យមកចាប់យកទៅជំនុំពិចារណាពិភក្សា ត្បិតចៅក្រម

សាលាអញស្គាល់អស់ហើយ ឱព្រាហ្មណ៍អើយ ពុំដែលស្គាល់គុកតារាងខ្នោះឃ្នាងច្រវ៉ាក់ច្រវាក់ តើអ្នកនឹងទប់ម្ដេចបាន ភ្នាក់ងារទាហានក៏នឹងវាយដំបែកជាឈាម ។ ជជូកស្រដីគម្រាមឲ្យតែព្រាហ្មណ៍ខ្លាចតែដោយនូវវាចា ឧបមាបីដូចគូររូបខ្លាឲ្យគោខ្លាច ។ ឯត្រកូលទាំងពីរនោះពុំអាចទប់ទល់បានឡើយ ហើយគិតគ្នាថា យើងមានទ្រព្យអ្វីនឹងយកទៅលក់ឲ្យតាជូជកនេះ សំពត់នៅចង្កេះក៏ចាស់ដាច់ដាច ថាសផ្តិលក៏បែកបាក់ ប្រណាកអកកំបោរក៏ឆែបឆា ជាទ្រព្យអន្ទការនឹងចាយវាយពុំបាន នឹងលក់ខ្លួនប្រាណក៏ពុំដាច់ បើដូច្នោះតើនឹងគិតធ្វើដូចម្ដេច ។ ភានអើយ! បើគិតទៅហើយមានតែកូនសម្លាញ់យើង គឺនាងអមិត្តតាបនានោះមិញ ជាកូនសម្លាញ់យើង, យើងនឹងលើកឲ្យតាជូជកចាស់ជរាជាភរិយាគាត់សិនចុះ បើដូច្នោះយល់ជាគាត់នឹងត្រេកអរពេញចិត្ត ត្បិតគាត់ក៏ចាស់ជរា ឯភរិយាក៏ក្រមុំព្រហ្មចារីយ៍ យល់បានដូចសេចក្ដីប្រាថ្នាគាត់ ៗ ស្លាប់កាលណាសឹមយកកូនយើងមកវិញអេះ ត្បិតព្រាហ្មណ៍នេះគាត់ក៏ចាស់ជរាណាស់ហើយ កាលណាឡើយ ក៏គាត់រស់នៅជាមនុស្សយឺនយូរទៅឯមុខ ទុកជាគេនិន្ទាថា

Websites: WatKhemaraRatanaram.org or WatKhmers.org

នាងអមិត្តតាបនាបានប្ដីចាស់ ក៏ដោយកលអេះ ឲ្យតែបានរួចអំពល់ អំពីទ្រព្យគាត់ ។ កាលនោះ តាជូជកគាត់ខេខឹងអង្គុយទ្រមឹងពុំនាំពា ខាកតែស្លានោះឮតែក្រខោកៗ គោះប៉ោកៗ លើកឡើងពមឆី ទើប នាងព្រាហ្មណីស្រដីប្រាប់តែដោយសេចក្ដីថា «នឹងឲ្យបុត្រីជាភរិយា» ទើបជូជកសួរថា «កូនអ្នកនោះ តើខ្មៅឬស ល្អឬអាក្រក់ហា:» តាជូជក គ្រាន់រីករាយ ។ ឯនាងព្រាហ្មណី ក៏អធិប្បាដោយដំណើរសរសើរអ្ងួត បុត្រីនៃអាត្មាថាល្អណាស់អម្ចាស់អើយ ល្អដូចអ្នកគួសវាស នឹងយក ស្រីទាំងផ្កាសមកប្រៀបផ្ទឹមពុំបានឡើយ ។ ជូជកស្ដាប់ហើយថា អើ! បើដូច្នោះយកមកមើលអេះ ។ ទើបព្រាហ្មណ៍យកកូនទៅផ្ងូតទឹក លាបម្សៅប្រេងជាសូរេចស្រេច ស្លៀកសំពត់ដណ្ដប់ស្បៃ ប៉ប្រែប៉ប្រិម ញញឹមស្រស់ ចរចាពីរោះមានក្លិនពិដោរដូចអ្នកអប់ផ្កានាំទៅ ។ ឯតា ជូជកលួចគន់មើលតែកន្ទុយភ្នែក ក្រឡេកមើលម្ដងៗ យល់បានដូច បំណងចិត្តគាត់ គិតនឹកតែក្នុងចិត្តថា «អេះល្អម៉្លេះជាម្ដងហ្ន៎» មើលទៅ យល់ជាគួគាប់ស័ក្តិសម មែនទែនវៃខ្វេនរៀបប្រដាប់ដាក់ទុក ទំនុក បំរុងនៅក្នុងវដ្ដសង្សារ អើយល់ជាប្រសើរពិតៗ បើនឹងឱបនឹងរឹត ក៏វា

Websites: WatKhemaraRatanaram.org or WatKhmers.org

ពេញដើមទ្រូង ។ តាជូជកគិតដូច្នោះហើយ ធ្វើកលជាមាយាស្រដីថា ‹‹យើងនេះមកសុំតែទ្រព្យគាប់អ្នកថាលំបាក ហើយគិតយកបុត្រីមកឲ្យជាភរិយាយើង ៗ ក៏ពុំសូវប្រាថ្នាទេ តែថាអ្នកឲ្យយើងហើយ នឹងលែងទទួលពុំបាន យើងនឹងនាំថ្កានឋានយើងឯនាយ ឥឡូវនេះឯងហោង›› ។ ទើបនាងព្រាហ្មណីជាម្ដាយមកស្រដីផ្ដែផ្ដាំផ្ដាក់ផ្ទុកផ្ញើបុត្រីលើតាជូជក តាមអាសូរករុណានាងអមិត្តតាបនា ហើយបបោសអង្អែលថា ‹‹ឱកូនពិសីសំឡាញ់មាសម្ដាយអើយ ម្ដាយពុំមានទ្រព្យអ្វីឲ្យឡើយ ម្ដាយនៅសព្វថ្ងៃនេះ ក្រខ្សត់ពេកណាស់ ម្ចាស់ម្ដាយអើយ ចូរនាងទៅនៅនឹងតាជូជក កុំបីមានទុក្ខសោករោគភ័យជម្ងឺតម្កាត់មកបៀតបៀនឡើយ›› ។ ជូជកស្ដាប់ហើយឆ្លើយថា ‹‹ម៉ែ ៗ កុំគិតឡើយ ខ្ញុំធានារក្សាឲ្យដូចមាតាបិតាទាំងពីរ ចំណេរទៅមុខ មាតាបិតានឹងបានជាមុខទុកជាកេរ្តិ៍អង្វែងវែងឆ្ងាយ›› ។ ជូជករួសរាយក្សេមក្សាន្ត នាំនាងអមិត្តតាបនាពីឋាននោះទៅតាមផ្លូវមាគ៌ា នាងអមិត្តតាបនា ក៏ស្ពាយយាមតាមតាព្រឹទ្ធាចារ្យពីក្រោយ ។ ឯតាជូជកដើរទៅហើយ ក្រឡេកមើលរឿយៗ ហាក់ដូចពុំនឿយហត់ឡើយ ហើយឲ្យនាងអមិត្តតាបនា

Websites: WatKhemaraRatanaram.org or WatKhmers.org

ដើរទៅមុនវិញ នឹងបានគន់មើលឲ្យស្កប់ចិត្ត គាត់គិតក្រែងក្មេងកំឡោះ វាមកដំបូចលួចសើចលេងនឹងនាងអមិត្តតាបនា ។ ជូជកជាទុក្ខនឹងដើរទៅមុខពុំបាន នឹងឲ្យខានដើរជាក្រោយក្រែងវាមកដំបូចលេង តែក្នុងចិត្តគិតឲ្យដើរទៅឯមុខ ហើយជូជកដើរពីក្រោយ ។ ក្សិណ ហើយស្រូតឡើងទៅខាងៗ សរសើរថា «ល្អមែន» ។ ជូជកដើរវិលទៅវិលមកដូចជាបាតខ្មៅ នាំទៅដល់លំនៅ ប្រដៅឲ្យធ្វើការងាររកធីតាមប្រពៃណីនោះឯងហោង ។ ឰដ៏កាលនោះ ឯនាងអមិត្តតាបនាប្រណិប័តន៍រក្សាតាព្រឹទ្ធាចារ្យដ៏ជាស្វាមី ពុំហ៊ានស្រដីខ្ចីខ្វាទ្រគោះ ឲ្យព្រាហ្មណ៍នោះរកឧស ចឹសស្រូវ ដណ្តាំបាយ ដងទឹកព្រឹកល្ងាចសព្វទិនទិវា ។ ឯព្រាហ្មណ៍ចាស់ ក៏មានចិត្តស្រឡាញ់នាងអមិត្តតាបនានោះមិញ ស្មើរនឹងលេបបាន ពុំឲ្យនាងអមិត្តតាបនានោះអាក់អន់ចិត្តដល់តិចឡើយ ។

អថ សព្វេ អញ្ញេ តរុណាព្រាហ្មណា ។ បពិត្រអើយ ឯអស់ព្រាហ្មណ៍កំឡោះផងទាំងឡាយ វាយល់នាងអមិត្តតាបនាប្រណិប័តន៍រក្សាតាជូជក ជាមនុស្សអាក្រក់អន្ធការ ទើបបណ្តាល ឲ្យខឹងនឹងភរិយា

របស់អាត្មារាល់គ្នា ហើយជេរថា «មេជូជាតិឥតខ្មាស់ ហាងដឹងតែដើរផ្កាសឥតស័ព្ទ ម្ដេចក៏ហាងមិនត្រាប់នាងអមិត្តតាបនា ស្អាងតែអាត្មាថាតែមាត់ មិនគិតធ្វើការរកឆីចុក មិនដងទឹក កាច់ឧស អង្គុយតែដុសក្រចក ធ្វើខ្លួនលាបតែក្រមួនឆីស្លា បន្តិចថាជា បន្តិចថាឈឺថ្កាត់ យកតែវន្ទះមាត់នោះមកគ្របលើប្ដី នឹងលក់ដូរអ្វីក៏ខាតទុន ស៊ុនទាំងចំណេញ បើនឹងរវៃមិញ បីថ្ងៃបីយប់ទើបបាន ១ ដែក បើនឹងត្បាញសំពត់វិញ តែមួយនឹងគេនោះកន្លះខែប្លាយ រវល់តែកាច់កនិយាយបញ្ចើប្រុស ហ៊ិស! មេកញ្ចើផ្លូះ វាយកតែពាក្យនោះជាទំនិញលលក់លាបប្រេងផាត់មុខមួយថ្ងៃពីរបីស្របក់ ឆ្លុះកញ្ចក់ពីរបីវេលា គំនិតស្មុគទ្រុឌ ទំនើងតែដើរលេងដោយរាល់ផ្ទះ នឹងរកអ្វីប្រាសក៏គ្មាន, រៀនតែជឿគេឆី ពុំគិតវែងឆ្ងាយ អញនឹងលែងក្បាលហាងឲ្យជាមេម៉ាយពុំស្ដាយឡើយ ។ អញនឹងរកទៀត ហើយឲ្យមានឥរិយាដូចនាងអមិត្តតាបនា ភរិយាតាជូជកនោះឯងហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ យំ អត្ថំ រឺអាថ៌ធម៌ឯណា ៨ ចាគដំ ពុំទាន់ប្រាកដ សត្ថា រឺព្រះបរមសាស្ដាចារ្យ បកា-

សេដ្ឋោ កាលព្រះអង្គទ្រង់ប្រកាស តំ អត្ថំ នូវអត្ថនោះ ចាកជំ ឲ្យប្រាកដច្បាស់ អាហ ក៏ទ្រង់សូត្រសាជាបាទព្រះគាថាដូច្នេះ ៖

អហុ វាសី កលិង្គេសុ ជូជកោ នាម ព្រាហ្មណោ
តស្សាបិ ឧហរា ភរិយា នាមេនាមិត្តតាបនា
តា នំ តត្ថ គតាវោចុំ នទីឧទកហារិយា
ថិយោ នំ បរិភាសឹសុ សមាគន្ត្វា កុតូហលា ។
អមិត្តា នូន តេ មាតា អមិត្តោ នូន តេ បិតា
យេ តំ ជិណ្ណស្ស បាទំសុ ឯវំ ឧហរិយំ សតឹ ។
អហិតំ វត តេ ញាតី មន្តយឹសុ រហោគតា
យេ តំ ជិណ្ណស្ស បាទំសុ ឯវំ ឧហរិយំ សតឹ ។
ទុក្កដំ វត តេ ញាតី មន្តយឹសុ រហោគតា
យេ តំ ជិណ្ណស្ស បាទំសុ ឯវំ ឧហរិយំ សតឹ ។
បាបកំ វត តេ ញាតី មន្តយឹសុ រហោគតា
យេ តំ ជិណ្ណស្ស បាទំសុ ឯវំ ឧហរិយំ សតឹ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

អមណាបំ វត តេ ញាតី　　មង្គយឹសុ រហោកតា
យេ តំ ជិណស្ស ចាគំសុ　　ឃរំ ទហរិយំ សតិំ ។
អមណាបកាសំ វសិ　　ជិណ្ណេន បតិណា សហ
យា ត្វំ វសសិ ជិណ្ណស្ស　　មតន្តេ ជីវិតា ឃរំ ។
ន ហិ នូន តុយ្ហំ កល្យាណីបិតា មាតា ច សោភនេ
អញ្ញំ កត្តារំ វិន្ទឹសុ
យេ តំ ជិណ្ណស្ស ចាគំសុ　　ឃរំ ទហរិយំ សតី ។
ទុយិដ្ឋន្តេ នវមិយំ　　អកាតំ អគ្គិហុត្តកំ
យេ តំ ជិណ្ណស្ស ចាគំសុ　　ឃរំ ទហរិយំ សតិំ ។
សមណេ ព្រាហ្មណេ នូន　　ព្រហ្មចរិយបរាយនេ
សា ត្វំ លោកេ អភិស្សសិ　　សីលវន្តេ ពហុស្សុតេ
យា ត្វំ វសសិ ជិណ្ណស្ស　　ឃរំ ទហរិយំ សតិំ ។
ន ទុក្ខំ អហិណា ទដ្ឋំ　　ន ទុក្ខំ សត្តិយា ហតំ
តញ្ច ទុក្ខញ្ច តិព្វញ្ច　　យំ បស្សេ ជិណ្ណកំ បតិំ ។

នត្ថិ ខិឌ្ឌា នត្ថិ រតិ ជិណ្ណេន បតិនា សហ
នត្ថិ អល្លាបសល្លាបោ ជគ្ឃិតម្បិ ន សោភតិ ។
យទា ច ទហរោ ទហរា មន្តយឹសុ រហោគតា
សព្វេ សោកា វិនស្សន្តិ យេ កេចិ ហទយស្សិតា
ទហរា ត្វំ រូបវតី បុរិសានំភិបត្ថិតា
គច្ឆ ញាតិកុលេ អច្ឆ កឹ ជិណ្ណោ រមយិស្សតីតិ ។

ភិក្ខវេ ម្នាលសង្ឃទ្រង់សីលផងទាំងឡាយអើយ ឥត្ថិយោ រីនាងព្រាហ្មណីផងទាំងឡាយ មានសេចក្តីអាស្រូវភាសខ្មាសគេ ត្បិតស្វាមីជេរកណ្តាលជំនុំ ទើបមកភ្ជុំគ្នានិន្ទានាងអមិត្តតាបនាថា «ពីដើមស្វាមីយើងនេះ ពុំដែលខេខឹងឃោរជេរពោលយើងដល់ម្ល៉េះ ឥឡូវនេះប្តីយើងខឹងឃោរជេរពោលជាកោលាហល អំពល់ទាំងស្រុក ទាំងភូមិព្រោះមេប្រពន្ធព្រាហ្មណ៍ស្ទួមវាមកនៅនេះ ទើបប្តីយើងកើត ក្តៅក្រហាយជេរវាយយើងរាល់គ្នា ថាបើយើងឲ្យមេនេះវានៅទៅឯមុខយើងនឹងកើតទុក្ខទោសច្រើនគ្រប់គ្នា កាលណាឡើយយើងនឹងបានសុខសប្បាយ មកយើងនឹងបបួលគ្នា ទៅជេរវាយស្រដីត្មះតិះដៀលវា

ដោយនូវតម្រិះប្រាជ្ញា រំអាឲ្យវាខ្លាចទើបបាន កុំឲ្យវានៅឋាននេះនឹងយើងបានឡើយ បើឲ្យវានៅនេះហើយ ប្ដីយើងនឹងជេរវាយយើង ព្រោះមេប្រពន្ធព្រាហ្មណ៍ចង្រៃនេះឯងជាប្រាកដពុំខានឡើយ ។ មកយើងនាំគ្នាទៅចាំឯកំពង់ទឹកជាមុនឱ្យហើយ ។ ពុំលង់ឡើយ ក៏បបួលគ្នាចុះទៅឯកំពង់ទឹកនោះ ។ លុះនាងអមិត្តតាបនាកណ្ដៀតក្អមមកទៅដងទឹក នឹងយកទៅឲ្យតាជីងូតផឹកជាប្រក្រតី, ឯអស់នាងព្រាហ្មណីយល់ហើយ ក៏ជេរទ្រគោះបញ្ឆោះនាងអមិត្តតាបនាលេង ជាឆោឡោអឹងកង បីដូចសត្វក្អែកឃើញចំណី ខ្លះស្រដីពីមុខ ខ្លះស្រដីពីខ្នង ខ្លះឈោងចាប់ដៃ ជេរផ្ដាលប្រទេចផ្ដាសា ដៀលដល់ម្ដាយឪពុក ដល់ត្រកូលវង្ស ភោតិ នៃ! នាងអមិត្តតាបនាអើយ ឯងមានរូបរាងដូចជាងគួសវាស ទោះឯងយាងយាសលីលាយាត្រា ភក្ត្រាស្រេចស្រស់ បើប្រុសឯណាគេឃើញស្មើរនឹងសន្លប់ទប់ពុំបាន អើម្ដេចក៏ឯងមកមានប្ដីចាស់ជូជាតិ ស្មើរគេយកខ្មោចឧត្បាតចង្រៃមកដាក់ប្រាណដូច្នោះ ។ ឯឯងបានជាស៊ុនខ្លួនធូនគ្រោះ តែគឺមោះចិត្តឯងនោះពុំប្រាជ្ញា រីឯងនេះជាស្រីខ្ជីខ្ជាអប្រិយ ជាស្រីអប្បយស ឃើញតែប្រុសក៏ត្រេកអរ ដូច

Websites: WatKhemaraRatanaram.org or WatKhmers.org

ជាគេឃើញស្អុរនិងទឹកឃ្មុំ ពុំធ្វើការងាររកឆីមកជាអម្រស់ អស់ក៏ពុំដឹងគង់ក៏ពុំដឹង គិតតែដើរលេងដោយផ្ទះគេ ពុំដឹងទិសដំបន់ឡើយ លុះតែល្ងាចហើយទើបវិលមកផ្ទះអាត្មាវិញ ។ មន្តយឹសុ រហោគតា រីអស់ញាតកាម្តាយឪពុកនឹងទុកដាក់ហាងពុំបាន ក្រែងមានអាស្រូវភាសទើបគេលើកហាងឲ្យតាជូជកចាស់ជរា ជាមនុស្សពិការអសោចដូច គេយកខ្មោចមកធ្វើជាប្តី យល់អប្រិយពុំសម ឬហាងយកមកបន្ទុំលេងទេម្តេចមិនមើលមុខមើលក្រោយ ហាងឃើញតែប្រុសក៏ដោយងាយ ៗ ឲ្យបង់ខ្លួនដូច្នោះ ឬមួយក្រែងកម្លោះគេពុំប្រាថ្នា គេយល់ហាងជាមនុស្សឥតសព្វឥតសារ ។ ទុក្ខាដំ មិនជាការប្រយោជន៍ ឲ្យតែអសោចអាស្រូវ ត្បិតចិត្តហាងពុំត្រូវនឹងអស់ចិត្តស្រីៗ នឹងរក្សាចិត្តប្តីពុំបាន ជាមនុស្សឥតសន្តានទុជិនពន់ពេក ទើបគេពុំយក ។ អញ្ញំ ភត្តារំ ចូរហាងស្វែងរកប្តីឯណា ឲ្យល្អមសមគួរ ឲ្យត្រូវចិត្តពិតប្រសើរពេកក្រៃលែងជាងចាស់ជរានេះវិញ ។ ទុយិដ្ឋនេ្ត រីហាងនេះធ្វើបូជាហោមពិធីមិនល្អឥវមិយំ ក្នុងតិថីថ្ងៃគំរប់ប្រាំបួន ទើបគេលើកឲ្យទៅតាជូជកចាស់ជរាឧបមាបីដូចក្អែកកញ្ជាស់ នាំយកពងមាន់ទៅឆី ឬមួយហាងបានប្រមាថ

Websites: WatKhemaraRatanaram.org or WatKhmers.org

សមណព្រាហ្មណ៍ ជី ថេរ ភិក្ខុសង្ឃ ពុំទាន់ទៀងត្រង់តាមប្រពៃណី ទើបហាងបានប្ដីចាស់ទៀបនឹងចូលលោង ខ្នងកោងកូក់ដូចទំពក់ឈើ តើក្នុងព្រះនគរនោះ មិនមានប្រុសទេឬ? អើ! អមិត្តតាបនាអើយ ហាងស្ដាយថ្វីជីវិតរស់នៅ សូវស្លាប់ទៅជាខ្មោចប្រសើរជាង ។ អហិនា ឧឌ្ឌំ ថាបើអាសិរពិសវានឹងខាំឲ្យអស់ជីវិត គួរអធិដ្ឋានទៅតាមផល កុំអំពល់នឹងខ្លួនឡើយ ។ សត្តិយា ហតំ ថាបើហាងដើរយប់ ចេញពីផ្ទះទៅហើយ ទៅប្រទះនឹងអ្នកពិឃាដជីវិតបង់ ក៏ប្រសើរក្រៃលែង នឹងរស់នៅជាមនុស្សវិញ ។ ឧហាពេ ឧហាភ ពាក្យបុរាណលោកពោលរៀងៗ មកថា «បើប្រពន្ធក្រមុំទើបសមនឹងប្ដីកម្លោះ» គួរគប្បីកាន់កោះរួមស្នេហា ។ រហោគតា តាមប្រពៃណីនាទីស្ងាត់ ឥឡូវនេះហាងមកបានប្ដីមនុស្សសាត់ព្រាត់ដូចយក្ខ ដូចមារ បើនឹងស្រដីសំណេះសំណាល ដូចគេខឹងគ្នា បើនឹងស្រដីជានា ដូចជាគេខម បើនឹងស្រដីលោម ដូចជាគេខាំ នេះហេតុតែកម្មហាងឯងនាំមកឲ្យប្រទះ ហេតុនេះ ចូរហាងឯងវិលទៅផ្ទះវិញ រកញាតកាម្ដាយឪពុកគេនឹងរៀបទុកដាក់ហាង ឲ្យមានប្ដីទៀត ឲ្យសក្តិសមនឹងប្រាណ ឲ្យបានរក្សាគ្នា

Websites: WatKhemaraRatanaram.org or WatKhmers.org

ជាយឺនយូរបរិបូណ៌ទៅឯមុខឯងហោង ។

សា តាសំ សន្តិកា បរិភាសំ លភិត្វា ។ រីនាងអមិត្តតាបនា កាលណាបើបានឮអស់នាងព្រាហ្មណី គេស្រដីខឹងឃោរ ជេរពោលវាយដំត្បិះដៀលដូច្នោះហើយ រីប្រមាត់នាងស្ទើរនឹងបែកសញ្ជែកប្រេះចេញ ឯក្អមទឹកនោះមិញក៏ទម្លាក់ព្រឹសអំពីចង្កេះ ថាអេះចាំអញទៅប្រាប់តាអញហា: វានឹងធ្វើអ្វីអញ វាម្ទេញនឹងអញ ថ្វីបើគាត់ចាស់ក្តីគ្រាន់រកចិញ្ចឹមគ្នាតាមក្រ បើរូបល្អតើនឹងលាងទឹកផឹកផ្អែតកាលណា ហើយនាងអមិត្តតាបនាដើរទៅដោយផ្លូវយំរង៉ូវតែឯង ។ ឯតាជូជកនោះកូវ គាត់អង្គុយនៅបង្អួចឃើញតែរោមស្រមូវ បីដូចស្វាព្រាមនៅលើឈើ លុះឮនាងអមិត្តតាបនាស្រដីយំបណ្តើរ ហើយគាត់ដណ្តឹងថា អមិត្តតាបនាសំឡាញ់តាអើយ ថ្វីហើយក៏បានជាយំព្រាហ្មណ៍ខំសួរខ្សឹកខ្សួលអួលក្នុងចិត្តអាណិតភរិយាសម្លាញ់ ទឹកភ្នែកនោះមិញវាហូរសស្រាក់ ពាហ្មណោឌ បុដ្ឋា អួលអាក់អម្ទេញដណ្តឹងទៅវិញទៀតថា «ថ្វីហើយថ្វីហ៎ា:! ម្ចាស់តា ក៏បានជាយំ អ្នកណាគេធ្វើនាង ចូរនាងប្រាប់តាមើលណ៎ាមាសតា ។ ទើបនាងអមិត្តតាបនាឆ្លើយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ថា «អើវាល្អហើយ បរិភាសន្តិ នៃតាចាស់អើយ អស់ប្រពន្ធព្រាហ្មណ៍កំឡោះ វាភ្ជុំគ្នាមកវាយជេរអញ ហាក់ដូចខ្ញុំលោះនឹងប្រាក់ចាក់អំពីថង់ពុំស្មើឡើយ» ។

ន តេ ព្រាហ្មណ គច្ឆាមិ     នទឹំ ឧទកហារិយា
ជិយោ មំ បរិភាសន្តិ     តយា ជិណ្ណេន ព្រាហ្មណាតិ។

ព្រាហ្មណ៍អើយ ម៉្លេះហើយអញមិនទៅឯកំពង់ទឹកដូចសព្វមួយដងវិញទៀតឡើយ ទាំងទឹកទាំងឧស ក៏អញពុំទៅដងទៅរកទៀតឡើយ ព្រាហ្មណ៍អើយ ព្រោះតែអញមកនៅបម្រើប្ដីចាស់នេះហើយទើបអស់ប្រពន្ធព្រាហ្មណ៍កំឡោះផងទាំងឡាយ វាមកកំហែងជេរវាយអញ ហាក់ដូចគេដណ្ដើមប្ដីឬសាហាយវា ជេរទាំងម្ដាយ កាយទាំងឪពុក ត្មះតិះដៀលមិនមានកោតក្រែង ថាជាស្រីអប្រិយ មានប្ដីកញ្ជាស់នេះឯង អញខឹងណាស់លើសអ្វីៗ ណាំតាអើយ ទាំងនេះព្រោះនរណា ព្រោះតែអញមកនៅនឹងតានាឋាននេះឯង ។

មា មេ ត្វំ អករា កម្មំ     មា មេ ឧទកមាហរិ
អហំ ឧទកមាហិស្សំ     មា ភោតី កុប្បិតា អហូតិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ទើបជូជកសំណោះសំណាលស្រដីលោមថា ម្ល៉ោះហើយ នាងកុំចេញទៅធ្វើការអ្វី ចូរនាងនៅតែក្នុងផ្ទះណា៎ម្ចាស់តា ទាំងទឹក នូវឧស នូវអស់បណ្ណាការអាហារផង នាងកុំទៅរកឡើយ ជាងារតាឯងហើយ នឹងផានាខ្វល់ខ្វាយទៅដង ទៅរកមកឲ្យនាងបរិភោគឱ្យជាសុខ កុំនាងជាទុក្ខឡើយណាអមិត្តតាបនា ចូរនាងរក្សាតែឈើច្រត់ នូវយាមឲ្យល្អ គ្រាន់តាដើររកជាអម្រស់អម្រ ឯរបស់នៅផ្ទះកុំឲ្យខូចបាត់បង់ឡើយ ។

ឯនាងអមិត្តតាបនាស្តាប់ហើយ ក៏ពុំត្រូវចិត្ត គិតក្តៅរោលរាលដូចភ្លើង អ្នកបំពក់ឲ្យឆួរឆេះព្រៃ ទើបនាងអមិត្តតាបនាពោលថា «តាកុំស្រដីពាក្យនេះ អញពុំយកពាក្យតាទេ» ។

ជាហំ តម្ហិ កុលេ ជាតា យំ ត្វំ ឧទកមាហរេ
ឯវំ ព្រាហ្មណ ជានាហិ ន តេ វច្ឆាមិហំ ឃរេ ។
សចេ មេ ទាសំ ទាសី វា ជានយិស្សសិ ព្រាហ្មណ
ឯវំ ព្រាហ្មណ ជានាហិ ន តេ វច្ឆាមិ សន្តិកេតិ ។

មានច្បាប់ឯណាប្រើប្តីតាងខ្ញុំ កុំស្រដីដូច្នោះឡើយ នៃតា

Websites: WatKhemaraRatanaram.org or WatKhmers.org

អើយទុកប្ដីស្មើឪពុក ជាទីគោរពប្រណិប័តន៍កោតខ្លាច ឯស្រីកំណាចជួជាតិអប្រិយ ទើបយកប្ដីជាខ្ញុំ ពុំត្រូវច្បាប់ជេរសាប់ដូចជ្រញ់ បើតាស្រឡាញ់អញនេះតាកុំនៅ ចូរទៅរកខ្ញុំស្រីខ្ញុំប្រុសមកឲ្យអញប្រើជាគ្នាជាដៃជើង ចូរតាទៅកុំខាន បើតារកពុំបាន អញនឹងរត់ទៅឋានលំនៅអញ ឥឡូវនេះឯងហោង ។

ផុជកោ អាហ

នត្ថិ មេ សិប្បដ្ឋានំ វា ធនំ ធញ្ញញ្ច ព្រាហ្មណិ
កុតោហំ ទាសឹ ទាសំ វា អានយិស្សាមិ ភោតិយា
អហំ ភោតឹ ឧបដ្ឋិស្សំ មា ភោតី កុប្បិតា អហុតិ

រីឯជូជកព្រឹទ្ធាចារ្យ លុះឮភរិយាស្រដីដូច្នោះហើយ ធ្វើកលមាយាស្រដីអួតអំពីទ្រព្យធនឲ្យប្រពន្ធស្ដាប់ ពីដើមមកវែងមានទ្រព្យមួយជញ្ជើង ពីរជញ្ជើង ទុកសម្រាប់ចាយប្រើនៅលើផ្ទះពុំដែលក្រ ខ្ញុំកំដរដ៏មាន ឥឡូវនេះតាមកបានក្ដីក្រីក្រលំបាក ទាំងស្រូវអង្ករនឹងរកឆីក៏គ្មាន អន្តរធានទាំងទ្រព្យ ត្បិតភ្លើងឆេះផ្ទះអស់ពុំគង់ ប្រពន្ធក៏ស្លាប់បង់ចោលគ្នាកំព្រានៅតែម្នាក់ឯង សព្វថ្ងៃឆីក៏ពុំឆ្អែតឆ្អន់ នាងក៏យល់នឹង

Websites: WatKhemaraRatanaram.org or WatKhmers.org

ភ្នែកស្រាប់ហើយ ។ ឧត្តិ មេ សិប្បដ្ឋានំ ក ទាំងសិល្បវិជ្ជាការ ក៏សាបសូន្យភ្លាំងភ្លាត់ ទាំងប្រក្រតីទិន ក៏ពុំចាំស្ទាត់ដូចក្បួនខ្នាត ភ្លេច ទាំងសូត្រព្យាត្រដួងជតា នឹងគុណានឹងហារ ក៏វិលវល់ពុំអស់សេចក្ដី នឹង គន់គូរមើលជតារាសី ក៏មិនឆុតដូចតម្រា ខំតែថាផ្សេងផ្សំ នឹងមើល អាគ្នេយ៍ចាក់អារក្សធំ ក៏ពុំប្រាកដដូចមុនមាន សព្វថ្ងៃនេះ អាងតែដើរ សូមទានគេមកចិញ្ចឹមអាត្មា ចូរនាងប្រើតាតែនៅអាយ តានឹងខ្វល់ ខ្វាយតាមនាងប្រើតានោះឯងហោង ។

បពិត្រអើយ ព្វដ៏កាលនោះ វីម្រឹត្យដែលនៅចាំតឿនអាយុតា ព្រឹទ្ធាចារ្យ បណ្ដាលឲ្យនាងអមិត្តតាបនា នឹកទៅដល់ព្រះបាទស្រី វេស្សន្តរបវរពោធិសត្វទៅសាងព្រឹទ្ធនៅក្នុងព្រៃ ទើបនាងអមិត្តតាបនា ស្រដីនឹងតាព្រឹទ្ធាចារ្យ សូត្រជាបាទគាថាដូច្នេះ ៖

ឯហិ តេ អហមក្ខិស្សំ   យថា មេ វចនំ សុតំ
ឯស វេស្សន្តរោ រាជា   វង្កេ វសតិ បព្វតេ ។
តំ ត្វំ គន្ត្វាន យាចស្សុ   ទាសំ ទាសិញ្ច ព្រាហ្មណ
សោ តេ ទស្សតិ យាចិតោ   ទាសំ ទាសិញ្ច ខត្តិយោ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ហៃព្រាហ្មណ៍អើយ អញឮដោយពាក្យគេថា វេស្សន្តររាជា មានព្រះមហាក្សត្រាធិរាជមួយព្រះអង្គ ទ្រង់ព្រះនាមព្រះបាទស្រីវេស្សន្តរ ស្តេចគ្រងព្រះនគរធំ អស់ក្សត្រផងតែងមកបង្គំជាប្រក្រតី ព្រះអង្គមានព្រះរាជហឫទ័យកាត់ដំឡាសទ្ធា មេត្តាករុណាអស់ស្មូមយាចកតោកយ៉ាកផង តែងមកអាស្រ័យព្រះអង្គ បើនឹងសូមអ្វី ក៏បានដូចចិត្តបំណងប៉ងប្រាថ្នា ព្រះអង្គតែងទ្រង់ព្រះរាជសទ្ធា ព្រះរាជទានពុំរួញរា ព្រះរាជទានទាំងដំរីគជសារ ឲ្យទានទៅព្រាហ្មណ៍តាមចិត្តពុំគិតស្តាយឡើយ ។ នែតាព្រាហ្មណ៍អើយ ទើបអស់អ្នកស្រុកគេញុះញង់សម្តេចព្រះវររាជបិតាព្រះអង្គ ឲ្យទ្រង់ព្រះក្រោធបណ្តេញព្រះអង្គឲ្យចេញចាកជេតុត្តរបុរី ព្រះអង្គនាំព្រះអគ្គមហេសី នូវព្រះរាជបុត្រទៅនៅនាភ្នំគិរីវង្កតបពិត ថាបើតាជីតាមទៅសុំព្រះរាជទាន ខ្ញុំប្រុសខ្ញុំស្រី យល់ថាព្រះអង្គព្រះរាជទានពុំខានឡើយ ។

កាលនោះ តាជូជកព្រឹទ្ធាចារ្យ ស្តាប់ភរិយាប្រាប់ដូច្នោះហើយ នឹងនៅស្ងៀមពុំបាន នឹងខានខ្លាចប្រពន្ធដែរ ទើបគាត់ប្រែភក្ត្រក្រកលអធិប្បាយដោយយោបល់ថា ៖

Websites: WatKhemaraRatanaram.org or WatKhmers.org

ជិណ្ណោហមស្មិ ទុព្វលោ ជីឃោ ចន្ទា សុទុក្ខមោ
មា ភោតី បរិទេវេសិ មា ភោតី វិមនា អហុ
អហំ ភោតឹ ឧបដ្ឋិស្សំ មា ភោតី កុប្បិតា អហូតិ ។

ហៃអមិត្តតាបនាសំឡាញ់តាអើយ តានេះចាស់ហើយទាំងភ្នែកក៏ងងឹត ទាំងត្រចៀកក៏ថ្លង់ ឯរោគក្នុងអង្គក៏ច្រើន បន្តិចគ្រុន បន្តិចរងា បន្តិចជា បន្តិចឈឺ វាអប់ឡប់តែក្នុងប្រាណ តែងសុំទានគេតែដោយរៀងអាយ ក៏ស្មើររកកាយនឹងដៃ នឹងឡើងឈើព្រៃក៏ពុំរហ័ស រីឯផ្លូវដែលនឹងទៅនោះក៏ឆ្ងាយណាស់ សឹងតែគ្រោកដំបូកក្រួសរវានស្មើរនឹងដើរពុំបានឡើយ បើប្រទះនឹងសត្វកំណាចហើយ នឹងស្លាប់ឥតការ ឯខ្លួននាងនឹងនៅអសារជាមេម៉ាយ វិមនា អមិត្តតាបនាសំឡាញ់តាអើយ នាងកុំជាទុក្ខពេកឡើយ ផានាលើតាឯងហើយ នឹងទៅរកមកចិញ្ចឹមនាង កុំបីនាងព្រួយចិត្តខឹងសម្បានឹងតាឡើយ ។

ឯនាងអមិត្តតាបនា កាលណាបានស្តាប់ពាក្យតាជូជកព្រឹទ្ធាចារ្យ ស្រដីត្អូញត្អែរពុំចង់ទៅ ថាផ្លូវកម្រឆ្ងាយ ទើបនាងស្រដីឧបមាឲ្យប្តីស្តាប់ថា ៖

Websites: WatKhemaraRatanaram.org or WatKhmers.org

យថា អគន្ធា សង្គាមំ　　អយុន្ទេវ បរាជិតោ
ឯវមេវ តុវំ ព្រហ្មេ　　អគន្ធារ បរាជិតោ ។
សចេ មេ ធាសំ ធាសី វា　　ធានយិស្សសិ ព្រាហ្មណា
ឯវំ ព្រាហ្មណា ជាជាហិ　　ន តេ វច្ឆាមិហំ ឃរេ
អមធាបន្តេ ការិស្សាមិ　　តន្តេ ទុក្ខំ ភវិស្សតិ ។
នក្ខត្តេ ឧតុបុព្វេសុ　　យថា មំ នក្ខសិ លង្កតំ
អញ្ញេហិ សទ្ធឹ រមមានំ　　តន្តេ ទុក្ខំ ភវិស្សតិ ។
អនស្សនេន មយ្ហន្តេ　　ជិណ្ណស្ស បរិទេវតោ
ភិយ្យោ វង្កា បលិតា ច　　ពហូ ហេស្សន្តិព្រាហ្មណាតិ។

ហៃតាជីអើយ មានឧបមាបីដូចសេនាសេនីយ៍ ស្រដីតែមាត់ចិត្តកម្លាច ស្រដីថាពុំខ្លាចត្រង់ស្លាប់ឡើយ លុះលើកទ័ពចេញទៅហើយ យល់ឯផង់ផុយធូលី ក៏ថាគេលើកទ័ពចូលមកតាំង ទើបបញ្ឈប់ទ័ព រើសរកទាហានអាសា បញ្ជូនតែសេនាទៅមុខ ទំរាំគេលើកទៅស៊ុន ទើបឯងធ្វើជាទ័ពទុនឯក្រោយ ឲ្យគេថាឯងជាទាហានក្លាហាន

Websites: WatKhemaraRatanaram.org or WatKhmers.org

ឧបមាបីដូចតាជូជក ពុំទាន់ចេញផុតពីផ្ទះ ក៏ត្អូញត្អែរបណ្តើរ ពុំទាន់ចុះផុតពីជើងជណ្តើរក៏ត្អូញថា ផ្លូវឆ្ងាយដាច់ស្រយាល បើដូច្នេះអញនឹងផាយរត់ទៅឯផ្ទះអញវិញហើយ ឥតោ្វត្តេ បើដល់ចូលឆ្នាំថ្មីមិញ អញនឹងទៅលេងជាមួយនឹងអស់កំឡោះផង មំ ឥត្វាសិ លឌ្គំតំ អញនឹងចុកចងស្មៀតសក់ដណ្តប់ស្បៃពណ៌ សៀតផ្កានួនស្រី នូវអស់ផ្កាផងទាំងឡាយ ស្លៀកសំពត់ឲ្យជជាយជជូរឲ្យស្រួលចិត្ត ឲ្យជូជកព្រាហ្មណ៍គាត់អង្គុយពត្លក់យំ កើតទុក្ខតែម្នាក់ឯង ដរាបលុះតែស្លាប់ទៅហោង ។ ព្រាហ្មណ៍អើយ ថាបើព្រះស្តែងទៅរក ទាសំ ទាសី វា ខ្ញុំប្រុសខ្ញុំស្រីមកបម្រើអញហើយ ព្រាហ្មណ៍អើយ អញនឹងទៅធ្វើការចាំព្រះស្តែងឯផ្ទះ បិទសម្រាស់ស្រាស់របងមិនឲ្យអ្នកផងមើលងាយអញ នោះតានឹងសប្បាយចិត្ត ត្បិតពុំបារម្ភមកផ្ទះឡើយ ។

តំ សុត្វា ព្រាហ្មណោ ឯតាជូជកព្រឹទ្ធាចារ្យ លុះឮភរិយាស្រដីដូច្នោះហើយ ក៏កើតចិត្តទាហានពុំខ្លាចព្រៃ ព្រោះគាត់លុះក្នុងអំណាចស្ត្រី ដោយក្តីមាតុគ្រាមតណ្ហា ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ រីអាថ៌ធម៌ឯណាពុំ

Websites: WatKhemaraRatanaram.org or WatKhmers.org

ទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ ហើយ ព្រះអង្គសំដែងនូវព្រះបាទព្រះគាថា ដូច្នេះ

តតោ សោ ព្រាហ្មណោ ភីតោ ព្រាហ្មណិយា វសានុគោ
អដ្ដិតោ កាមរាគេន ព្រាហ្មណិំ ឯតទព្រវិ ។
ចាបេយ្យំ មេ ករោហិ ត្វំ សង្ក៉ុលា សង្ក៉ុឡានិ ច ។
មធុបិណ្ឌិកា ច សុកតាយោសត្តុភត្តញ្ច ព្រាហ្មណិ ។
អានយិស្សំ មេថុនកេ ឧភោ ទាសកុមារកេ
តេ ច បរិចរិស្សន្តិ រត្តិន្ទិវមត្តន្ទិតាតិ ។

ភិក្ខវេ ម្នាលសង្ឃដ៏ទ្រង់សីលសង្វរទាំងឡាយ ឯតាជូជកព្រឹទ្ធាចារ្យនោះ លុះក្នុងអំណាចនាងព្រាហ្មណី ដោយក្ដីមាតុគ្រាមតណ្ហា ឮតែភរិយាស្រដីដូច្នោះក៏ភ័យខ្លាចប្រពន្ធមិនស្រឡាញ់ ទើបស្រដីនឹងនាងព្រាហ្មណីដូច្នេះថា ចាថេយ្យំ មេ ករោហិ ចូរនាងអមិត្តតាបនា វណ្ដាប់ស្បៀងដាក់ថង់យាម តាមមានតាមបាន តានឹងយកទៅទាំងទ្រាបលាជ ទ្រាបល្ង ទាំងសដូវដុំ សដូវថង់ មិនដូចនៅផ្លូវជិត

រៀងអាយនឹងបានវិលមកវិញឆាប់ តានឹងប្រញាប់ទៅក្រាបទូលសុំព្រះរាជកុមារទាំពីរព្រះអង្គ មកធ្វើជាទាសាទាសី ។ នែអមិត្តតាបនាសម្លាញ់ថៅតាអើយ ព្រះរាជកុមារទាំងពីរ ពុំមានសេចក្តីខ្ជិលច្រអូសនឹងមកនៅបម្រើនាងទាំងយប់ទាំងថ្ងៃ កុំឲ្យសម្លាញ់តាព្រួយ ចិត្តពេកឡើយ ។

សា ចិប្បំ ចាបេយ្យំ បដិយាទេត្វា ឯនាងអមិត្តតាបនា ឮថាតាជូជកនឹងទៅនាថ្ងៃនោះ នាងក៏ខ្វល់ខ្វាយចាយទិញហាក់ដូចមានការអាពាហ៍ពិពាហ៍ ម្ទីម្ទាមករណ្តាប់ឲ្យតាជូជកដោយសព្វគ្រប់ប្រការ ។ រីឯតាជូជកព្រឹទ្ធាចារ្យ ព្រួយចិត្តគិតតែនាងអមិត្តតាបនាស្រដីថា អញព្រួយចិត្តត្បិតទៅយូរឆ្នាំ ពុំមានប្រុសនៅចាំផ្ទះសោះ ក្រែងគ្រាន់កក់ក្តៅ ហើយគាត់ឈ្មោកទៅក្នុងគ្រឹហា តេហេទុព្វលដ្ឋានំ យល់ជញ្ជាំងក៏ដាច់ ទ្វារក៏បាក់ ឆ្មៀងក៏ធ្លាក់ដូចគេរាយដោយដី ថិរំ កត្វា ជួជកក៏ជួសឡើងជាថ្មីវិញ ទ្វារំ បដិសង្ខរិត្វា ជួសជុលទាំងទ្វារជណ្តើរផ្ទះ ស្រាស់របង ហើយទៅដងទឹកមកទុកឲ្យផឹកឲ្យងូត បូរេត្វា ពេញទាំងក្រឡពិន្ទងពុំមានឲ្យសល់ ហើយទូន្មាន

Websites: WatKhemaraRatanaram.org or WatKhmers.org

នាងអមិត្តតាបនា ដ៏ជាភរិយាសំឡាញ់ យាវជ្ជតណា តាំងពីថ្ងៃនេះរៀងទៅមុខ អប្បមត្តា ចូរនាងកុំប្រហែស ចូរនាងប្រយ័ត្នខ្លួនស្ងួនរក្សាក្រែងកើតមានភ័យ ត្បិតប្ដីទៅឆ្ងាយក្រែងគេមើលងាយ មួយសោត កុំដើរដោយផ្ទះព្រៀងលានពុំជាគេនឹងនិន្ទាជាអាស្រូវ ចូរនាងនៅផ្ទះសង្វាតតែរកឆីទម្រំប្ដីមកដល់ ហើយតាជូជកទប់ទល់ពុំបានក៏ប្រះប្រាណយំសោកស្រណោះអាឡោះអាល័យ ហើយអង្អែលភក្ត្រាបបោសខ្នងនាងអមិត្តតាបនា ផ្ដាំស្រេចហើយ ពុំយូរឡើយតាជីក៏យកថង់ស្បៀងដាក់លើស្មា ហត្ថាចាប់ឈើច្រត់ បជត្វិណំ កត្វា ហើយដើរប្រទក្សិណ ៣ ជុំ អស្សុបុណ្ណេហិ នេត្តេហិ ហើយគាត់ឈានជើងចេញដើរទៅ ទឹកភ្នែកក៏ហូរសស្រាក់ឥតស្បើយ បក្កាមិ ពុំយូរឡើយគាត់ដើរចេញទៅអំពីឋានលំនៅនោះឯងហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសាន្ទូវបាទព្រះគាថាដូច្នេះ៖

ឥទំ វត្វា ព្រាហ្មណោ បដិមុញ្ចិ ឧបាហនំ

Websites: WatKhemaraRatanaram.org or WatKhmers.org

តតោ សោ មន្តយិត្វាន ភរិយំ កត្វា បទក្ខិណំ ។
បក្កាមិ សោ រុណ្ណមុខោ ព្រាហ្មណោ សហិតព្វតោ
សិវីនំ នគរំ ផីតំ ជាសបរិយេសនព្វារត្ថិ ។

ជូជកជាពូជពង្សវង្សត្រកូលព្រាហ្មណ៍ ពោលពាក្យផ្តាំផ្ញើនាងអមិត្តតាបនាស្រេចហើយ ក៏ពាក់ស្បែកជើងដើរប្រទក្សិណភរិយា តាព្រាហ្មណ៍ក៏មានទឹកភ្នែកហូរសស្រាក់ សមាទានវត្តជាតាបសឥសី ហើយត្រាច់ចរទៅកាន់នគរអ្នកស្រុកស្រីពិរាស្រ្ត ដ៏ជាស្រុកធំទូលាយស្តុកស្តម្ភ ដើម្បីដើររកសុំទាសាទាសី លុះតាជីងងុលជជ្រុលជ្រុកដោយផ្លូវទៅដល់ជេតុត្តរនគរបវររាជឋានហើយ បានឃើញមហាជនគេអង្គុយជួបជុំគ្នា ក៏ចូលទៅសួររកព្រះបាទស្រីវេស្សន្តរថា ក្វហឹវេស្សន្តរោ រាជា រីព្រះបាទស្រីវេស្សន្តរបវរខត្តិយវង្ស តើព្រះអង្គគង់នៅឋានឯណាហ្ន៎ អ្នកទាំងឡាយប្រាប់ខ្ញុំឲ្យបានដឹងផង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសាន្ទូវបាទព្រះគាថាដូច្នេះ ៖

Websites: WatKhemaraRatanaram.org or WatKhmers.org

សោ តត្ថ គន្ត្វា អវចាសិ    យេ តត្ថាសុំ សមាគតា
កុហឹ វេស្សន្តរោ រាជា    កត្ថ បស្សេមុ ខត្តិយំ ។
តេ ជនា តំ អវចឹសុ    យេ តត្ថាសុំ សមាគតា
តុម្ហេហិ ព្រហ្មេ បកតោ    អតិទានេន ខត្តិយោ
បព្វាជិតោ សកា រដ្ឋា    វង្កេ វសតិ បព្វតេ ។
តុម្ហេហិ ព្រហ្មេ បកតោ    អតិទានេន ខត្តិយោ
អាទាយ បុត្តទារញ្ច    វង្កេ វសតិ បព្វតេតិ ។

នគរវាសិនោ រីអស់អ្នកនគរទាំងឡាយនោះ លុះបានស្តាប់ពាក្យតាជីសួរ អំពីព្រះបាទស្រីវេស្សន្តរ បវរពោធិសត្វ ក៏មានចិត្តខឹងឃោរនឹងតាព្រាហ្មណ៍ជេរតាមសព្វអំពើថា «អើតាព្រាហ្មណ៍នេះឯងហើយ វាតែងមកបៀតបៀនយាយីព្រះអង្គ វាពុំចង់រកឆីចុកលលក់ទន្និញ ចង់សុំអ្វីមិញក៏សុំទាល់តែបាន ឯព្រះអង្គតែងទ្រង់ព្រះរាជទានសំពត់អាវព្រៃព្រំនឹងអ្វីៗ ពុំដែលខាន សុំទាំងដំរីបច្ច័យនាគេន្ទ្រដ៏ជាដំរីមង្គល នាំឲ្យកើតអំពល់ដល់បណ្តារាស្ត្រ គេនាំគ្នាខឹងអស់ទាំងព្រះនគរ ទាល់តែព្រះវររាជបិតាទ្រង់ព្រះក្រេវក្រោធនឹងព្រះអង្គ ទើបស្តេច

Websites: WatKhemaraRatanaram.org or WatKhmers.org

ឲ្យបំបរបង់ចេញពីព្រះរាជដ្ឋាន ឯព្រះរាជហឫទ័យពុំមានរួញរា ពួកព្រាហ្មណ៍អស់នេះ វាបបួលគ្នាទៅតាមសុំព្រះរាជរថ និងសេះអាជា-នេយ្យទាំង ៤ ពុំមានចិត្តអាណិតប្រណីព្រះអង្គឡើយ ។ ព្រាហ្មណ៍នេះឯងហើយ វាក្បត់នឹងផ្ទៃក្រោម នៃគ្នាយើងអើយ មកយើងចោមចាប់សម្លាប់វាឲ្យហើយ ទើបផ្ទៃក្រោមយើងនឹងរាប លេឌ្ឌុឧណ្ហាឌិហត្ថាខ្លះក្រោកឡើងប្រវាចាប់បានឈើព្រៃ ដុំដី នូវតដ្ឋដេញប្រកិតតាមទៅឯតាជូជករត់ចូលទៅក្នុងព្រៃ ហាត់ស្ទើរតែនឹងក្ស័យជីវិតដោយភិតភ័យហេតុតែទេវតាបញ្ចូលចិត្ត ទើបគាត់ដើរទៅជួបនឹងផ្លូវទៅភ្នំគិរីវង្កតបពិតនោះឯងហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសានូវបាទព្រះគាថាដូច្នេះថា

សោ ចោទិតោ ព្រាហ្មណិយា ព្រាហ្មណោ កាមគិទ្ធិមា
អយន្តំ បដិសេវិត្ថ
វនេ វាឡមិគាកិណ្ណេ ខគ្គឌីបិនិសេវិតេ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

អាទាយ វេឡុំ ឧណ្ឌំ　　អគ្គិហុត្តំ កមណ្ឌលុំ
សោ ចារិសិ ព្រហារញ្ញំ　　យត្ថ អស្សោសិ កាមទំ ។
តំ បវិដ្ឋំ ព្រហារញ្ញំ　　កោកា ឆំ បរិវារយុំ
វិក្កន្ទិ សោ វិប្បនដ្ឋោ　　ទូរេ បន្ថា អបក្កមិ ។
តតោ សោ ព្រាហ្មណោ គន្ត្វា　　ភោគលុទ្ធោ អសញ្ញតោ
វង្ក័ស្សោហរណេ នដ្ឋោ　　សុនខេហិ បរិវារិតោ
រុក្ខស្មិញ្ច និសិន្នោ វ　　ឥមា គាថា អភាសថាតិ ។

ភិក្ខវេ ម្នាលសង្ឃដ៏ខ្លាចភ័យក្នុងវដ្ដសង្សារ សោ ជូជកោ រីឯតាជូជកព្រឹទ្ធាចារ្យជាអ្នកហិនហោច ដើរត្រមោចចូលទៅក្នុងព្រៃព្រឹក្សា យំសោកពិលាបអនាថអាណិត កាមតិទ្ធិមា ព្រោះត្បិតតណ្ហាវារោលរាលក្នុងមនោទ្វារ ទើបគាត់យកភេទជាតាជី ដើរស្រុកប៉ប្រុកទាំងទុក្ខ ពភ្លាក់ពភ្លើ វេឡុំ ឧណ្ឌំ កាន់ឈើច្រត់ពណ៌លឿងទុំ ស្នាស្ដាយយាមតតែងតតោកដូចគេធ្វើលេង ជូជកឈឺចិត្តខ្លួនឯងពន់ពេកកន្លង ចារិសិ ព្រហារញ្ញំ គាត់ដើររលេះរលាំងចូលទៅក្នុងព្រៃ

Websites: WatKhemaraRatanaram.org or WatKhmers.org

ធំ ដង្គុំរបោះចន្លោះជើងភ្នំ តាមច្រកតូចធំ ជ្រោះជ្រលងដងស្ទឹងបឹងបួ ញាតស្បាតស្បូវផ្លូវចន្លោះ ឫស្សីដុះសាញសឹងបន្លា មាគ៌ាក៏ចង្អៀត ជូជកខំដើរជ្រៀតតែម្នាក់ឯង ក្រែងខ្លាចភ័យ ភ្នែកតែងរំពៃទៅមុខ ក្រោយឆ្វេងស្តាំ ក្រែងប្រទះនឹងខ្លាដំរីក្របីព្រៃរមាស សឹងបន្លឺសព្ទ សំឡេងដាសពាសពេញទាំងព្រៃ ។ ជូជកមានភ័យសត្វស្ទើរបាត់ ព្រលឹងគាត់ខំតែប្រឹងដើរដែកញែកបន្លាស្បូវស្បាត ឲ្យបានរំលងទ្វារ ព្រៃទៅពីផ្លូវកម្រ គោកកា ធំ បរិវារយុំ ជូជកដើរជជ្រុលជជ្រកទៅ ពុំ លង់ឡើយ ក៏ស្រាប់តែប្រទះនឹងឆ្កែចេតបុត្រ វារត់មកដេញព្រាហ្មណ៍ នោះមិញ វាចោមព្រុសជុំវិញ ឯតាជូជកខំរត់ខ្មាញ់សស្ទើតសស្លក់ភិត ភ័យ ហើយស្រែកថា ឆ្កែៗ ឯឆ្កែរឹងជាដេញព្រុសប្រកិត តាជីខំរត់ដៃ កាន់ឈើច្រត់លើកឡើងឃាររាំងរា ប្រយ័ត្នហាត់ហាហុះពោះនោះផើត ផតៗ ភ្នែកសស្លឹង ប្រឹងលោតឡើងទៅលើចុងព្រឹក្សា ហើយស្រែក ទួញយំរកព្រះបាទស្រីវេស្សន្តរបវរពោធិសត្វ សូត្រជាបាទព្រះគាថា ដូច្នេះថា ៖

គោកា រាជបុត្តំ និសកំ ជយន្តមបរាជិតំ

Websites: WatKhemaraRatanaram.org or WatKhmers.org

ភយេ ខេមស្ស ធាតារំ កោ មេ វេស្សន្តរំ វិទូ ។
យោ យាចតំ បតិដ្ឋាសិ ភូតានំ ធរណីរិវ
ធរណូបមំ មហាភាគំ កោ មេ វេស្សន្តរំ វិទូ ។
យោ យាចតំ គតី អាសិ សវន្តីនំវ សាគរោ
ឧទកូបមំ មហាភាគំ កោ មេ វេស្សន្តរំ វិទូ ។
កល្យាណតិត្ថំ សុបិរំ សីតូទកំ មនោរមំ
បុណ្ឌរីកេហិ សញ្ឆន្នំ យុត្តំ កិញ្ជក្ខរេណុនា
រហទូបមំ មហាភាគំ កោ មេ វេស្សន្តរំ វិទូ ។
អស្សត្ថំវ បថេ ជាតំ សីតច្ឆាយំ មនោរមំ
សន្តានំ វិសមេតានំ កិលន្តានំ បដិគ្គហំ
តរូបមំ មហាភាគំ កោ មេ វេស្សន្តរំ វិទូ ។
និគ្រោធំវ បថេ ជាតំ សីតច្ឆាយំ មនោរមំ
សន្តានំ វិសមេតានំ កិលន្តានំ បដិគ្គហំ
តរូបមំ មហាភាគំ កោ មេ វេស្សន្តរំ វិទូ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

អម្ពំ ឥវ បថេ ជាតំ សីតច្ឆាយំ មនោរមំ
សន្តានំ វិសមេតានំ កិលន្តានំ បដិគ្គហំ
តថូបមំ មហាភជំ កោ មេ វេស្សន្តរំ វិទូ ។
សាលំ ឥវ បថេ ជាតំ សីតច្ឆាយំ មនោរមំ
សន្តានំ វិសមេតានំ កិលន្តានំ បដិគ្គហំ
តថូបមំ មហាភជំ កោ មេ វេស្សន្តរំ វិទូ ។
ទុមំ ឥវ បថេ ជាតំ សីតច្ឆាយំ មនោរមំ
សន្តានំ វិសមេតានំ កិលន្តានំ បដិគ្គហំ
តថូបមំ មហាភជំ កោ មេ វេស្សន្តរំ វិទូ ។
ឯវញ្ច មេ វិលបតោ បវិដ្ឋស្ស ព្រហាវនេ
អហំ ជានន្តិ យោ វជ្ជា នន្ទិំ សោ ជនយេ មម ។
ឯវញ្ច មេ វិលបតោ បវិដ្ឋស្ស ព្រហាវនេ
អហំ ជានន្តិ យោ វជ្ជា វេស្សន្តរនិវាសនំ
តាយ សោ ឯកវាចាយ បសវេ បុញ្ញំ អនប្បកន្តិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

កោ បុគ្គលោ ឱបុគ្គលឯណាអើយ ញ៉ាំងមានដំណឹង ដឹងទីលំនៅអាស្រមព្រះបរមវេស្សន្តរបវរពោធិសត្វ ព្រះអង្គមកសាងព្រះផ្នួសបួសជាឥសី ជយន្តមបរាជិតំ ព្រះអង្គឈ្នះមច្ឆរិយធម៌ ដ៏ជាអន្ទាក់ច្រវាក់ណែងណង ទ្រង់ឲ្យបានដល់នូវព្រះនិព្វាន ។ ព្រះអង្គតែងមានព្រះទ័យចង់ឲ្យបានសេចក្តីសុខ ពុំឲ្យមានទុក្ខដល់អស់អ្នកផងទាំងឡាយ ព្រះអង្គទ្រង់ធម៌ជាទីពំនាក់នៃស្មូមយាចកទាំងឡាយដូចជាព្រះធរណីជាទីពំនាក់នៃសព្វសត្វទាំងឡាយ ។ មួយវិញទៀតព្រះអង្គជាទីប្រជុំចូលគាល់នៃពួកស្មូមយាចក ដូចជាមហាសមុទ្រជាទីប្រជុំហូរចុះនៃស្ទឹងទន្លេទាំងឡាយ ព្រះបាទស្រីវេស្សន្តរមហាក្សត្រថ្លៃប្រសើរនោះ ព្រះអង្គមានឧបមាដូចជាស្រះស្រង់ មានកំពង់រាបទាបស្រួល អ្នកផងចុះទៅងូតទឹកផឹកបានដោយងាយ មានទឹកថ្លាត្រជាក់ដ៏ដេរដាសដោយឈូកស ឈូកច្រាល ដ៏មានលំអងកេសរផ្ការោយរាយផ្សាយក្លិនក្រអូបឈ្ងុយឈ្ងប់ ពុំនោះសោត មានឧបមាដូចដើមពោធិព្រឹក្ស ដើមជ្រៃ ដើមស្វាយ ដើមរាំង ឬដើមឈើធំៗ ដទៃទៀត ដែលមាននៅជិតផ្លូវ ជាទីត្រាច់ទៅមកនៃមហាជនដែលនឿយណាយហត់

Websites: WatKhemaraRatanaram.org or WatKhmers.org

អស់កម្លាំង ក៏ចូលឈប់សំរាកកាយបានតាមប្រាថ្នា ព្រោះព្រឹក្សាអស់នោះ មានម្លប់សាខាត្រឈឹងត្រឈៃត្រជាក់ស្រួលសប្បាយក្នុងរដូវក្តៅ មានឧបមាដូចម្តេចមិញ ព្រះបាទស្រីវេស្សន្តរមហារាជក្សត្រថ្លៃប្រសើរនោះ មានឧបមេយ្យដូច្នោះដែរ ។ ឱអ្នកឯណាអើយបានដឹងថា ឥឡូវនេះ ស្តេចគង់នៅទីណា មេត្តាប្រាប់ខ្ញុំតាជីបន្តិចវ៉ា ឱអ្នកឯណាអើយមានចិត្តអាណិត ជួយប្រាប់លំនៅព្រះបាទស្រីវេស្សន្តរបវរពោធិសត្វដោយវាចា ១ ម៉ាត់ថា ខ្ញុំដឹងប៉ុណ្ណោះ ខ្ញុំតាជីមានបីតិត្រេកអររកអ្វីប្រៀបគ្មាន ហើយអ្នកនោះនឹងបានកុសលផលបុណ្យច្រើន នឹងត្រារាប់ពុំបានឡើយ ។ តាជូជកស្រែកទ្រហោយំខ្សឹកខ្សួល រកព្រះបាទស្រីវេស្សន្តរ នៅនាព្រៃធំសម្បើមមហិមាតែម្នាក់ឯងហោង ។

តស្ស តំ បរិទេវសទ្ទំ អារក្ខនត្ថាយ ឋបិតោ ចេតបុត្តោ បពិត្រអើយ ឮដំកាលនោះ មានថ្មើព្រៃម្នាក់ឈ្មោះចៅចេតបុត្រ លោកសន្មតទុកឲ្យចាំរក្សាទ្វារព្រៃ គាត់ក៏ចេះសិល្បធ្នូបាញ់មុតមែនក្រៃនស្ទាត់ គាត់អាស្រ័យធ្វើជាផ្ទះស្រាស់របង ពុំឲ្យអ្នកផងដើរចូលទៅកាន់ភ្នំគិរីវង្កតបពិតបាន គាត់ក៏បណ្តើរនូវឆ្កែប្រមាណ ១ ស្រែ

Websites: WatKhemaraRatanaram.org or WatKhmers.org

ពីផ្លូវទៅកូវ គាត់ចូលទៅដល់ព្រៃធំ លុះឮសូរមាត់តាជូជកទ្រហោយំ ច្រឡំនីទៅនូវសំឡេងឆ្កែវាព្រុស ទើបចេតបុត្រក៏ម្នីម្នាក្រឡេកមើលទៅ យល់ឯព្រាហ្មណ៍ស្រមូវនៅលើចុងព្រឹក្សា ទើបចេតបុត្រលាន់មាត់ថា «ឱអញថាជាសត្វអ្វី មិនដឹងជាព្រាហ្មណ៍អប្រិយទេហ្ន៎ ម្ដេចក៏មកយំ សោករកព្រះបាទស្រីវេស្សន្តរបវរពោធិសត្វ ថាបើដោយអញរំពឹងគិត ទៅប្រហែលជាមកសុំព្រះរាជបុត្រាបុត្រី ឬសម្ដេចព្រះរាជមេទ្រីទៅពុំ ខាន ។ បើដូច្នោះ អញនឹងសម្លាប់វាបង់ទៅក្នុងកាលឥឡូវនេះឯង» ។ ថាហើយចេតបុត្រម្នីម្នាប្រវាចាប់ផ្ទួដំឡើងក្រិត ខាំមាត់ក្រអឺត យកកាំ មកផ្ទាប់លើកត្រង់តម្រង់ទៅកូវ ស្រដីគម្រាមថា «អះព្រាហ្មណ៍អប្រិយ អើយ! អញមិនទុកជីវិតចៅឲ្យរស់នៅឡើយ» ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសាជាបាទព្រះគាថាដូច្នេះ

តស្ស ចេតោ បដិស្សោសិ អរញ្ញេ លុទ្ទកោ ចរោ ។
តុម្ហេហិ ព្រហ្មេ បកតោ អតិធានេន ខត្តិយោ

Websites: WatKhemaraRatanaram.org or WatKhmers.org

បព្វាជិតោ សកា រដ្ឋា  វង្កេ វសតិ បព្វតេ ។
តុម្ហេហិ ព្រហ្មេ បកតោ  អតិទានេន ខត្តិយោ
អាទាយ បុត្តទារញ្ច  វង្កេ វសតិ បព្វតេ ។
អកិច្ចការី ទុម្មេធោ  រដ្ឋា វិវនមាគតោ
រាជបុត្តំ គវេសន្តោ  ពកោ មច្ឆមិវោទកេ ។
តស្ស ត្យាហំ ន ទស្សាមិ  ជីវិតំ ឥធ ព្រាហ្មណ
អយំ ហិ តេ មយា នុន្នោ  សរោ ចាស្សតិ លោហិតំ ។
សិរោ តេ វជ្ឈយិត្វាន  ហទយំ ឆេត្វា សពន្ធនំ
បន្ថសកុណំ យជិស្សាមិ  តុម្ហំ មំសេន ព្រាហ្មណោ ។
តុយ្ហំ មំសេន មេទេន  មត្ថកេន ច ព្រាហ្មណ
អាហុតឹ បគ្គហេស្សាមិ  ឆេត្វាន ហទយំ តវ ។
តំ មេ សុយិដ្ឋំ សុហុតំ  តុយ្ហំ មំសេន ព្រាហ្មណ
ន ច ត្វំ រាជបុត្តស្ស  ភរិយំ បុត្តេ ច នេស្សសីតិ ។

ក្សិណនោះ ចេតបុត្រថ្មើរព្រៃ កំពុងត្រាច់រង្គាត់ទៅក្នុងព្រៃ

ព្ធជូជកស្រែកទ្រហោយំ រកព្រះបាទស្រីវេស្សន្តរបវរពោធិសត្វដូច្នេះ កូវ ចេតបុត្រក៏ស្រែកគម្រាមទៅថា «រឺយព្រាហ្មណ៍កញ្ជាស់ ម្ដេចក៏មកយំសោករកព្រះអង្គ បើដោយអញរំពឹងគិតទៅយល់ជាព្រាហ្មណ៍កញ្ជាស់នេះឯង មករកសុំទាន ទើបវាខំត្រាច់មកដល់អាយ ក៏វាសុំអ្វីមាល្បាយ តាំងពីព្រះអង្គគង់នៅក្នុងព្រះរាជវាំង ដរាបមកគង់នៅក្នុងភ្នំគិរីវង្កតបពិត វានាំគ្នាសុំទាំងដំរីបច្ច័យនាគេន្ទ្រក្ដី ជាដំរីព្រះទីនាំងដ៏ប្រសើរ ពួកវាសុំសព្វសុំគ្រប់ ពុំគិតប្រណីដោយក្ដីតណ្ហាលោភលន់ទាល់តែអ្នកនគរខឹងជាកោលាហល នាំគ្នាក្រាបទូលប្ដឹងផ្ដល់ សម្ដេចព្រះវររាជបិតា ឲ្យស្ដេចបំបរបង់ព្រះអង្គចេញចាកព្រះនគរ ។ ព្រះអង្គតោងនាំព្រះរាជបុត្រាបុត្រី និងព្រះរាជទេពីមកគង់នៅភ្នំគិរីវង្កត ។ ព្រាហ្មណ៍កញ្ជាស់នេះឯងហើយ ជាមនុស្សអប្បលក្ខណ៍ ខំដើរស្វះស្វែងមករកសូមព្រះរាជបុត្រាបុត្រី ដូចកលបក្សីគឺ កុក រនាល កាលឯណាបានយល់ត្រីក្នុងបឹង ត្រពាំង ក្នុងរដូវប្រាំងរីងទឹកហែងហួតហើយតែងហើរមកចាប់ចឹកឆី ដរាបលុះតែអស់ ។ ព្រាហ្មណ៍អប្រិយនេះឯងជាមនុស្សអន្ធពាលកំណាចអាចតាមបំផ្លាញព្រះអង្គជាប្រាកដ វាមិន

Websites: WatKhemaraRatanaram.org or WatKhmers.org

ចេះរកឆីចុកលលក់ទន្និញ ព្រាហ្មណ៍ចង្រៃអើយ កុំទន្ទឹងរកព្រះអង្គឡើយ អញពុំទុកជីវិតព្រះស្តេងឲ្យរស់នៅតទៅទៀតទេ អញបាញ់នឹងធ្នូឲ្យត្រូវដើមទ្រូងរូងយកថ្លើមប្រមាត់ញាំភ្លាបូជាក្រុងពាលី ធ្វើពលីការទេពរក្សាច្រកភ្នំ ឯក្បាលព្រះស្តេងសោត អញនឹងដោតថ្វាយអ្នកតានៅនាព្រៃភ្នំនេះ ។ ហ្អះ ព្រាហ្មណ៍កញ្ចាស់ចង្រៃ ព្រះស្តេងស្លាប់នឹងដៃអញឥឡូវពុំលែងឡើយ ។

សោ តស្ស វចនំ សុត្វា ។ រីឯតាជូជកព្រឹទ្ធាចារ្យ កាលឮពាក្យចេតបុត្រព្រានព្រៃ ស្រដីដណ្តឹងដូច្នោះហើយ គាត់ក៏ភិតភ័យញាប់ញ័រទាំងខ្លួនប្រាណ ស្ទើរបាត់ព្រលឹង ខំប្រឹងស្រដីទាំងញ័រមាត់អធិប្បាយសេចក្តីមុសាវាទ ទៅកាន់ចេតបុត្រ ដោយបាទព្រះគាថាដូច្នេះថា ៖

អវជ្ឈោ ព្រាហ្មណោ ទូតោ ចេតបុត្ត សុណោហិ មេ
តស្មា ហិ ទូតំ ន ហន្តិ ឯស ធម្មោ សនន្តនោ ។
និជ្ឈត្តា សិវិយោ សព្វេ បិតា នំ ទដ្ឋុមិច្ឆតិ ។
មាតា ច ទុព្វលា តស្ស អចិរា ចក្ខូនិ ជីយរេ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

តេសាហំ បហិតោ ទូតោ ចេតបុត្ត សិណោហិ មេ
រាជបុត្តំ ឆយិស្សាមិ យទិ ជាជាសិ សំស មេតិ ។

ចេតបុត្ត ហៃថៅចេតបុត្រជាសំឡាញ់អើយ អម្បាញ់មិញនេះ ថៅថាបាញ់ៗ តើថៅបាញ់អ្នកណាហ្ន៎ះ ? ចេតបុត្រឆ្លើយថា «អញមាននរណាជាសំឡាញ់នឹងអញ នៅនាកណ្ដាលព្រៃនេះ ឥតអង្គឹមានឡើយ នរណាស្រដីមកនឹងអញៗ នឹងបាញ់អ្នកនោះឯងហោង» ។ ទើបជូជកស្រដីថា ឱ! សំឡាញ់អើយ ម្ដេចក៏អ្នកស្រដីរឹងរូសប្រទូស្តពន់ប្រមាណ យល់តែឯងបានធ្នូពាយងាយ ទំនើងតែនឹងបាញ់ នៃសំឡាញ់អើយ រីអញនេះពុំមែនជាស្មូមយាចក តាមមកសុំទាននោះទេ ។ ហៃសំឡាញ់អើយ អញជាត្រកូលព្រាហ្មណ៍ធំ ឧត្តមប្រសើរក្រៃលែងព្រាហ្មណ៍ផងទាំងឡាយ អញតែងនឹងគិតការព្រះរាជពិធីតាមប្រពៃណីអំពីបុរាណ អញតែងនឹងប្រដៅសិល្ប៍សាស្ត្រព្រះរាជបុត្រ ឲ្យរៀនសូត្រទាំងពុទ្ធទាំងសេយ្យ ឥឡូវនេះ ព្រះបាទស្រីសញ្ជ័យ ដ៏ជាព្រះវររាជបិតា មានព្រះជរារោគាព្យាធិមកបៀតបៀនព្រះកាយ ពុំសប្បាយក្នុងព្រះអង្គ ទ្រង់ព្រះចិន្តានឹករលឹកដល់ព្រះរាជបុត្រទាំងពីរព្រះអង្គ

Websites: WatKhemaraRatanaram.org or WatKhmers.org

និងព្រះថៅទាំងពីរ ជាបណ្ដូលសង្សារ ទើបមានព្រះរាជឱង្ការ តម្រាស់ត្រាស់ប្រើអញមករកអារាធនា ព្រះអង្គស្រីវេស្សន្តរបវរពោធិសត្វ ឱ្យទៅគ្រប់គ្រងយោធាសេនាមន្ត្រី គួរអ្វីអ្នកនឹងសម្លាប់អញ ថាបើអ្នកសម្លាប់អញនឹងបានក្ដីខុសពីរប្រការ ត្បិតអញជាអ្នកនាំព្រះរាជសារកាន់ព្រះរាជអាជ្ញាព្រះបាទអ្នកជាម្ចាស់ ឯអញនេះជាត្រកូលព្រាហ្មណ៍ធំផង បើនឹងពិឃាដរាជទូតលោកតាមចិត្ត ឬមួយនឹងសម្លាប់ផ្ដាច់ជីវិតសមណៈជីព្រាហ្មណ៍ ក៏ពុំត្រូវនឹងប្រពៃណីអំពីបុរាណរៀងមកនោះឡើយ ។

តទា ចេតបុត្តោ រីឯចេតបុត្រព្រានព្រៃ លុះឮសំដីជូជកព្រាហ្មណ៍ថា ជាអ្នកកាន់ព្រះរាជអាជ្ញា មកអារាធនាព្រះបាទស្រីវេស្សន្តរបវរពោធិសត្វ ទៅគ្រប់គ្រងរាជសម្បត្តិ នាបុរីជ័យជេតុត្តរនគរនោះ សោមនស្សប្បត្តោ ក៏មានចិត្តត្រេកអរឥតឧបមា សុនខេ ពន្ធិត្វា ទើបចេតបុត្រចាប់ឆ្កែចងខ្ទាប់ កាប់ឈើមកពាក់ជាបង្ហោងឲ្យតាជីចុះកកិបកកាបពីចុងព្រឹក្សា ហើយឲ្យអង្គុយលើស្លឹកឈើធ្វើជាកម្រាលអាសនៈ ទើបឲ្យតាជីបរិភោគភោជនាហារ ត្រាតែឆ្អែតស្កប់ស្កល់

Websites: WatKhemaraRatanaram.org or WatKhmers.org

បដិសណ្ឋារំ  កាភេន្តោ  ចេតបុត្រព្រានព្រៃ  ក៏ធ្វើសេចក្តីសំណេះសំណាលប្រស្រ័យនឹងតាជូជក សូត្រជាបាទព្រះគាថាដូច្នេះ៖

បិយស្ស មេ បិយោ ទូតោ  បុណ្ណបត្តំ ទទាមិ តេ
ឥទញ្ច មធុនោ តុម្ពំ  មិគសត្ថិញ្ច ព្រាហ្មណ
តញ្ច តេ ទេសមក្ខិស្សំ  យត្ថ សម្មតិ កាមទោតិ ។

ហៃតាព្រឹទ្ធាចារ្យអើយ  យើងបានជាស្រដីទ្រគោះគម្រោះគម្រាមពិតជាទុច្ចរិតវាចា ស្មានជាអ្នកសូមទាន បានជាយើងខឹង ពុំចេរតែអ្នកតាអត់ទោសយើងបានម្តង  ឯអស់ស្បៀងអាហារផងនឹងរកឲ្យតាតាមកម្លាំង  មធុនោ  តុម្ពំ  ទាំងទឹកឃ្មុំខែប្រាំង សឹងដ៏មានឱជារសឆ្ងាញពិសា  មិគសត្ថិញ្ច  ទាំងសាច់ទ្រាយឆ្អើរ ចូរអ្នកតាយកទៅគ្រាន់ជាយាបនម័ត្តបំបាត់ស្រេកឃ្លានទៅឯមុខ យត្ថ  សម្មតិ  កាមទោ  រីឯព្រះអាស្រមបរមពោធិសត្វ  ព្រះអង្គសាងព្រតពោធិញ្ញាណជាទីបន្ទោបង់នូវកាមតណ្ហា  ទ្រង់ប្រព្រឹត្តនេក្ខម្មបារមីក្នុងព្រៃរហោស្ថាននៅទីឯណា  យើងក៏នឹងប្រាប់អ្នកតាឲ្យទៅរកព្រះអង្គត្រង់ទីប្រទេសនោះហោង ។

ជូជកាបព្វំ បពិត្រអើយ អាត្មាភាពសំដែងថ្លែងព្រះធម៌ វិសេសទេសនាព្រះមហាជាតក កណ្ឌជូជកនោះមិញ ដ៏ប្រដាប់ប្រដានី ទៅនូវព្រះគាថា ៥៩ ព្រះគាថា និដ្ឋិតំ ក៏ចប់បរិបូណ៌សមគួរដោយនូវវេលានេះឯងហោង ៕៚

(ចប់កណ្ឌជូជក ទី ៥ តែប៉ុណ្ណោះ)

---

វាយខំព្យូទ័រសាឡើងវិញ

ដោយ

**លោកគ្រូអាចារ្យ ឈឹម សំបូរ**

និង

ត្រួតពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ

ដោយ

លោកគ្រូ **ធម្មនាថ ផនប្រសិទ្ធី**

ដើម្បីផ្សព្វផ្សាយ ជូនជាធម្មទាន តាមវិបសាយ

សព្វធាជំ ជម្មធាជំ ជិជាតិ ធម្មទានឈ្នះអស់ទានទាំងពួង

ញ៉ុក . ថែម

# មហាវេស្សន្តរជាតក



កណ្ឌទី ៥

ផ្សាយចេញពី "[illegible]"
រក្សាសិទ្ធិគ្រប់យ៉ាង
ព.ស ២៥៤៦ គ.ស ២០០២